តួនាទីពិសេសរបស់ស្ត្រីនៅក្នុងការដោះស្រាយបញ្ហាប្រែប្រួលអាកាសធាតុ

UNIQUE ROLE of WOMEN in

DEALING WITH CLIMATE CHANGE

នៅតំបន់ទន្លេមេគង្គ
ការប្រែប្រួលអាកាសធាតុ
នឹងប៉ះពាល់ដល់ស្ត្រីធ្ងន់ធ្ងរ
ដោយសារស្ត្រីពឹង
ផ្អែកភាគច្រើនទៅលើធនធានធម្មជាតិ។

តាមទម្លាប់ស្ត្រី តែងចូលរួមក្នុងការងារគ្រប់គ្រង ការថែរក្សា និងអភិរក្សធនធានធម្មជាតិ សំរាប់ ការប្រើប្រាស់សម្ភារភាព និងសហគមន៍ ហើយស្ត្រីតែងមានចំណេះដឹងលំអិតពីបញ្ហាក្នុងមូលដ្ឋានរបស់ខ្លួន។

ការមិនអោយស្ត្រីចូលរួមក្នុងដំណើរការធ្វើសេចក្តីសំរេចចិត្តផ្សេងៗទាក់ទងនឹងការប្រែប្រួលអាកាសធាតុ ធ្វើអោយបាត់សម្លេងរបស់ប្រជាជនជាងពាក់កណ្តាលរបស់ពិភពលោក ធ្វើអោយ សង្គមបាត់បង់ជំនាញ បទពិសោធន៍ និងសមត្ថភាពពិសេសជាច្រើនដែលស្ត្រីមាន។

'MEKONG' the MOTHER

មេគង្គ ជាមាតា

ការពិតទៅ ការប្រើភាសាអង់គ្លេសថាទន្លេ “មេគង្គ” គឺជាការយល់ច្រឡំ។ នៅក្នុងភាសាថៃ និងឡាវ ពាក្យប្រើសំរាប់សំគាល់ទន្លេ គឺមេណាម ដែលមានន័យត្រង់ថាមាតាទឹក។ ប្រជាជនមូលដ្ឋាន ហៅខ្លីថា មេគង្គ ឬ “មេខុង” ។ ភាសាខ្មែរ សំរាយពីពាក្យមេគង្គ មានន័យត្រង់ថាគង្គទឹក។ មេ ឬម្តាយ បន្សំបានជាពាក្យមេគង្គដែលមានន័យដូចគ្នានឹងភាសាថៃ និងឡាវដែរ។ សំរាប់ប្រជាជនមូលដ្ឋាន ទន្លេគឺជាម្តាយដែលផ្តល់នូវជីវិ និងចិញ្ចឹមបីបាច់។ ជាទម្លាប់ ប្រជាជនមូលដ្ឋាន តែងគោរពទន្លេ និងសុំការអនុញ្ញាតពីទន្លេ មុននឹងប្រើប្រាស់ ធនធានមានក្នុង ទន្លេដែលជាមាតា ដើម្បីទ្រទ្រង់ ជីវភាពរស់នៅប្រចាំថ្ងៃ។



Mekong River Commission

Climate Change & Adaptation Initiative

គំនិតផ្តួចផ្តើមអំពីការប្រែប្រួលអាកាសធាតុ និងការបន្សាំទៅនឹងការប្រែប្រួល អាកាសធាតុរបស់គណៈកម្មការទន្លេមេគង្គ

Global Phenomenon
Regional Colaboration
Local Action

បាតុភូតសកលលោក

កិច្ចសហប្រតិបត្តិការក៏រិតតំបន់

សកម្មភាពមូលដ្ឋាន

ដោយសារកង្វល់ពិភពលោកអំពីការប្រែប្រួលអាកាសធាតុ កើនឡើង គណៈកម្មការទន្លេមេគង្គ មានទិសដៅរកអោយឃើញថាវាមានតើការប្រែប្រួលអាកាសធាតុមានន័យដូចម្តេចចំពោះ ប្រជាជនរស់នៅតាមអាងទន្លេមេគង្គ នៅក្នុងបរិបទដែលធនធានធម្មជាតិមានការប្រែប្រួល មានយ៉ាងដូចម្តេចចំពោះការប្រើប្រាស់ធនធានធម្មជាតិនាពេលអនាគត និងចំពោះផលប៉ះពាល់ លើបរិស្ថាន។

គំនិតផ្តួចផ្តើមអំពីការប្រែប្រួលអាកាសធាតុ និងការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុរបស់គណៈកម្មការទន្លេមេគង្គ គឺជាកិច្ចខិតខំប្រឹងប្រែង សហប្រតិបត្តិការក៏រិតតំបន់របស់ប្រទេសសមាជិកគណៈកម្មការទន្លេមេគង្គដែលរួមមាន កម្ពុជា ឡាវ ថៃ និងវៀតណាម។

ដើម្បីឆ្លើយតប និងសម្របខ្លួនទៅនឹងផលប៉ះពាល់ដោយការប្រែប្រួលអាកាសធាតុ គំនិតផ្តួចផ្តើមអំពីការប្រែប្រួលអាកាសធាតុ និងការបន្សាំទៅ ការប្រែប្រួលអាកាសធាតុរបស់គណៈកម្មការទន្លេមេគង្គ មានទិសដៅជួយដល់ប្រជាជននៅតាមតំបន់ទន្លេមេគង្គ មានជា អាទិ៍ :

- ការសិក្សាពីផលប៉ះពាល់ និងការលើកកំពស់ការយល់ដឹងអំពីការប្រែប្រួលអាកាសធាតុ។
- ការកែលំអ និងថែរក្សាប្រព័ន្ធអេកូឡូស៊ី
- ការលើកទឹកចិត្តអោយសហគមន៍ចូលរួមក្នុងដំណើរការ និងសកម្មភាពបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ។

ដោយមានការគាំទ្រពីគណៈកម្មការទន្លេមេគង្គ និងបណ្តាញអ្នកទំនាញយេនឌ័រថ្នាក់តំបន់ គំនិតផ្តួចផ្តើមអំពីការប្រែប្រួលអាកាសធាតុ និងការបន្សាំទៅតាមការប្រែប្រួលអាកាសធាតុ ប្តេជ្ញាបញ្ចូលក្របខ័ណ្ឌយេនឌ័រ តាមគ្រប់លទ្ធភាព ដូចជាការវិភាគផលប៉ះពាល់ផ្នែកសង្គម សេដ្ឋកិច្ច សកម្មភាពបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ និងគោលនយោបាយស្វែងរកការគាំទ្រ ដើម្បីទទួលបានប្រយោជន៍ពីចំណេះដឹង និងជំនាញពិសេសរបស់ស្ត្រី នៅក្នុង យុទ្ធសាស្ត្រសម្របខ្លួន និងដោះស្រាយបញ្ហាប្រែប្រួលអាកាសធាតុ។

អ្វីដែលសំខាន់ គឺធានាអោយបានថា គំនិតផ្តួចផ្តើមនេះ ផ្តល់ផលប្រយោជន៍ដល់បុរស និងស្ត្រីស្មើគ្នា ស្របទៅនឹងតំរូវការខុសគ្នា ហើយនិងការចូលរួមចំណែកដូចគ្នានៅគ្រប់លំដាប់ថ្នាក់។

Printed wtih soy ink.